## ៤- សមាទាន សីល ៥ (និច្ចសីល)

សីល៥មនុស្សក្នុងដែនកុរុគេរក្សាយូរណាស់មកហើយព្រះពុទ្ធទទួលយកសីល៥នេះមកប្រើហៅថានិច្ចសីល គឺសីលដែលគេត្រូវរក្សាជានិច្ច។ ពាក្យអារាធនាថា :

**-ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម** (៣)**។** ប្រែថា:សូមគោរពបពិត្រព្រះករុណាដ៏ចំរើនខ្ញុំព្រះករុណា ទាំងឡាយ សូមនូវសីលទាំងឡាយ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍និងរក្សាផ្សេងៗគ្នា ។

**-ទុតិយម្បិ..។** ជាគម្រប់ពីរដងផង... ។

**-តតិយម្បិ..។** ជាគម្រប់បីដងផង... ។

ព្រះសង្ឃអ្នកឲ្យសីលនាំថា ហើយអ្នកកាន់សីល ត្រូវថាតាម ដូចតទៅនេះ :

**-នមោ តស្ស... (៣ដង) ។** ដូចមានពន្យល់ខាងដើម រួចមក ហើយ ។

**-ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់ នូវព្រះពុទ្ធ ជាទីពឹងទីរលឹក,

**-ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវ ព្រះធម៌ជាទីពឹងទីរលឹក,

**-សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក,

**-ទុតិយម្បិ... ។** ជាគម្រប់ពីរដងផង... ។

**-តតិយម្បិ...។** ជាគម្រប់បីដងផង... ។

ព្រះសង្ឃថា **តិសរណគ្គហនំ បរិបុណ្ណំ** កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។ អ្នកកាន់សីល ទទួលថា **អាម ភន្តេ** ករុណា លោកម្ចាស់ ។

---

( ៣ ) បើ១នាក់ ប្រើ អហំ ជំនួស មយំ យាចាមិ ជំនួស យាចាម ។

# ព្រះសង្ឃ នាំថា សិក្ខាបទមួយៗ

១-**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណាសូមសមាទាន នូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា ធ្វើ សត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

២-**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាន នូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យ ដោយកាយ ឬ ដោយវាចា ។*

៣-**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។*

៤-**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។*

៥-**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ៕*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*